# ព្រឹត្តិបត្រព័ត៌មាន NEC BULLETIN គ.ជ.ប

លេខ២ ចេញផ្សាយថ្ងៃទី០៥ ខែមករា ឆ្នាំ២០១២


# ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣

( ថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២ )

## ពិធីចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយ នៅលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២



សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា






### មាតិកា


* ការកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត............ ទំព័រទី ២
* ចំនួនបេក្ខជនគណបក្សនយោបាយ ២ ដែលចូលរួមប្រកួតប្រជែង..................... ទំព័រទី ៤
* នីតិវិធីនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការដាក់ពាក្យបណ្តឹង............ ទំព័រទី ៥
* បណ្ណាល័យរូបភាពស្តីពីការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សា................ ទំព័រទី ៨
* ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ.................. ទំព័រទី ១៣


necinfo@forum.org.kh www.necelect.org.kh Fax/Phone: (023) 214 374, 214231, Tel: 012 855 018

# ការកំណត់លំដាប់លេខរៀងគណបក្សនយោបាយ នៅលើសន្លឹកឆ្នោតមានសារៈសំខាន់




តាមវចនានុក្រមខ្មែរភាគទី២ ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ ពាក្យថា *លំដាប់* មានន័យថា “របៀប ថ្នាក់ ជាន់ សង្កាត់”។ លំដាប់លេខរៀង ក្នុងភាសាអង់គ្លេសហៅថា Order មានន័យថា របៀបនៃការតំរៀបវត្ថុ ឬអង្គធាតុចាប់ពីពីរឡើងទៅ ដោយដាក់តាមលេខរៀង និងមានលំដាប់លំដោយ។

ការកំណត់លំដាប់លេខរៀងមានផលប្រយោជន៍ច្រើន ព្រោះអាចឱ្យយើងស្គាល់ ឬញែកវត្ថុពីរ ឬច្រើនឱ្យដាច់ដោយឡែកពីគ្នា និងមានភាពងាយស្រួលក្នុងការកំណត់ចំណាំ។

ដូចគ្នានេះដែរ ការកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ក៏ដើម្បីឱ្យអ្នកបោះឆ្នោតបានដឹង និងឈានទៅធ្វើការសម្រេចចិត្តជ្រើសរើសយកគណបក្សណាមួយ ក្នុងចំណោមគណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។



***តំណាងគណបក្សនយោបាយសង្កេតមើលការចាប់ឆ្នោត***

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២ ត្រូវបានសាធារណជនដឹងហើយថា មានគណបក្សនយោបាយចំនួន២បានចូលរួមប្រកួតប្រជែង គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសម រង្ស៊ី។

ដោយអនុវត្តតាមបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បាន រៀបចំពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីឈ្មោះគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ដែលពិធីនេះត្រូវធ្វើឡើងជាសាធារណៈ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១។ ពិធីចាប់ឆ្នោតកំណត់លំដាប់លេខរៀង





គណបក្សនយោបាយនៅលើសន្លឹកឆ្នោតបានប្រព្រឹត្តទៅក្រោមព្រះរាជាធិបតី សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមពីសមាជិក សមាជិកា មន្ត្រី គ.ជ.ប តំណាងគណបក្សនយោបាយ អង្គការសង្កេតការណ៍បោះឆ្នោត អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។

បន្ទាប់ពីសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះប្រទានការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតរួចមក គណបក្សប្រជាជនកម្ពុជា ទទួលបានលំដាប់លេខរៀងទី១ និងគណបក្សសម រង្ស៊ី ទទួលបានលំដាប់លេខរៀងទី២។

លទ្ធផលនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងរបស់គណបក្សនយោបាយនៅលើសន្លឹកឆ្នោត ត្រូវបាន គ.ជ.ប យកទៅធ្វើការបោះពុម្ពសន្លឹកឆ្នោត។ ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍នៅក្នុងពិធីនោះថា “លទ្ធផលនៃការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតមានអត្ថន័យសំខាន់ណាស់ ព្រោះការកំណត់លេខរៀងគណបក្សនយោបាយនីមួយៗនៅលើសន្លឹកឆ្នោតជួយបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយពាក់ព័ន្ធ ក្នុងការឃោសនាបោះឆ្នោត ការបោះឆ្នោត និងជួយឱ្យអ្នកបោះឆ្នោតអាចស្គាល់បានដោយងាយស្រួលនូវគណបក្សនយោបាយដែលគាត់ស្រឡាញ់ពេញចិត្ត”។

សូមបញ្ជាក់ថា គម្រោងថវិកាសម្រាប់ចំណាយទៅលើការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទាំងមូលមានប្រមាណ ២.២៨៧លានរៀល ស្មើនឹងជាង ៥៥ម៉ឺនដុល្លារ។ គ.ជ.ប នឹងបោះពុម្ពសន្លឹកឆ្នោតចំនួន ២៥.០០០សន្លឹក៕


**ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប**

អ្នកគ្រប់គ្រង លោក **ម៉ៃ សារី**

**ក្រុមនិពន្ធ**

លោក ជា សែ

លោក សុខ លាភ

**កំណែអក្ខរាវិរុទ្ធ**

អ្នកស្រី ទិន សាវត្ថី

**អ្នកថតរូប**

លោក សាក់ បូរិន

**ក្រាហ្វិកកុំព្យូទ័រ**

លោក ប៉េង រតនៈ

លោក ចាន់ វិបុល

# ចំនួនបេក្ខជននៃគណបក្សនយោបាយ ២ ដែលចូលរួមប្រកួតប្រជែង សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២

តាមស្ថិតិគណបក្សនយោបាយដែលបានចុះបញ្ជីតាមច្បាប់ស្ដីពីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ មានគណបក្សនយោបាយចំនួន៣៩។ ក្នុងចំណោមគណបក្សនយោបាយទាំងនោះ មានតែគណបក្សចំនួន២ប៉ុណ្ណោះ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះនៅ គ.ជ.ប ដើម្បីប្រកួតប្រជែងសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសម រង្ស៊ី។

គណបក្សនយោបាយទាំង២នេះបានចុះបញ្ជីបេក្ខជនគណបក្សរបស់ខ្លួននៅតាមមណ្ឌលភូមិភាគនីមួយៗរួមមាន គណបក្សប្រជាជនកម្ពុជាបានដាក់បេក្ខជនសរុបចំនួន ១១៤នាក់ក្នុងនោះពេញសិទ្ធិ ៥៧នាក់ និងបម្រុងចំនួន៥៧នាក់។ រីឯគណបក្សសម រង្ស៊ី បានដាក់បេក្ខជនសរុបចំនួន ១១៤នាក់ ក្នុងនោះពេញសិទ្ធិ ៥៧នាក់ និងបម្រុងចំនួន ៥៧នាក់។

ខាងក្រោមគឺជាចំនួនបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយទាំង២នៅតាមមណ្ឌលភូមិភាគនីមួយៗ ៖

| មណ្ឌលភូមិភាគ | ឈ្មោះរាជធានី ខេត្ត | ចំនួនអាសនៈ | គណបក្សប្រជាជនកម្ពុជា | | | | គណបក្សសម រង្ស៊ី | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនបេក្ខជនឈរឈ្មោះបោះឆ្នោត | | | | ចំនួនបេក្ខជនឈរឈ្មោះបោះឆ្នោត | | | |
| | | | ពេញសិទ្ធិ | | បម្រុង | | ពេញសិទ្ធិ | | បម្រុង | |
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ភូមិភាគទី ១ | រាជធានីភ្នំពេញ | ៦ | ៦ | ១ | ៦ | ១ | ៦ | ៣ | ៦ | ១ |
| ភូមិភាគទី ២ | ខេត្តកំពង់ចាម | ៨ | ៨ | ១ | ៨ | ២ | ៨ | ១ | ៨ | ០ |
| ភូមិភាគទី ៣ | ខេត្តកណ្ដាល | ៥ | ៥ | ១ | ៥ | ១ | ៥ | ១ | ៥ | ០ |
| ភូមិភាគទី ៤ | ខេត្តបាត់ដំបង<br>ខេត្តបន្ទាយមានជ័យ<br>ខេត្តសៀមរាប<br>ខេត្តឧត្តរមានជ័យ<br>ខេត្តប៉ៃលិន | ១០ | ១០ | ១ | ១០ | ១ | ១០ | ១ | ១០ | ១ |
| ភូមិភាគទី ៥ | ខេត្តតាកែវ<br>ខេត្តកំពត<br>ខេត្តកែប | ៧ | ៧ | ១ | ៧ | ១ | ៧ | ១ | ៧ | ៣ |
| ភូមិភាគទី ៦ | ខេត្តព្រៃវែង<br>ខេត្តស្វាយរៀង | ៧ | ៧ | ១ | ៧ | ២ | ៧ | ០ | ៧ | ១ |
| ភូមិភាគទី ៧ | ខេត្តកំពង់ស្ពឺ<br>ខេត្តកំពង់ឆ្នាំង<br>ខេត្តពោធិ៍សាត់<br>ខេត្តកោះកុង<br>ខេត្តព្រះសីហនុ | ៨ | ៨ | ១ | ៨ | ១ | ៨ | ១ | ៨ | ០ |
| ភូមិភាគទី ៨ | ខេត្តកំពង់ធំ<br>ខេត្តព្រះវិហារ<br>ខេត្តក្រចេះ<br>ខេត្តស្ទឹងត្រែង<br>ខេត្តរតនគិរី<br>ខេត្តមណ្ឌលគិរី | ៦ | ៦ | ១ | ៦ | ២ | ៦ | ០ | ៦ | ១ |
| | **សរុប** | **៥៧** | **៥៧** | **៨** | **៥៧** | **១១** | **៥៧** | **៨** | **៥៧** | **៧** |

# នីតិវិធីនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្តឹងតវ៉ា ឬជំទាស់ នៅការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប ក្នុងកម្មវិធីស្វែងយល់អំពីការបោះឆ្នោត

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២។

ពាក់ព័ន្ធនឹងការងាររៀបចំការបោះឆ្នោតនេះ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា បទបញ្ញត្តិសំខាន់ៗនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានតម្រូវឱ្យអនុវត្តនៅក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ព្រឹទ្ធសភាមាននីតិកាល៦ឆ្នាំ ហើយនឹងផុតកំណត់នៅពេលដែលសមាជិកព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ សមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៣នេះមានសមាជិក៦១រូប ក្នុងនោះមាន២រូបចាត់តាំងដោយព្រះមហាក្សត្រ ២រូបត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមការបោះឆ្នោតមតិភាគច្រើនដោយប្រៀប និង៥៧រូបទៀតត្រូវបោះឆ្នោតជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានេះ អនុវត្តតាមប្រព័ន្ធសមាមាត្រ ហើយការបែងចែកអាសនៈត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដោយយកភូមិភាគធ្វើជាមណ្ឌលបោះឆ្នោត។ មណ្ឌលភូមិភាគទាំងអស់មាន៨ ហើយភូមិភាគនីមួយៗត្រូវបានកំណត់ដោយយករាជធានី ឬខេត្តមួយ ឬច្រើន។

រហូតមកដល់ពេលនេះ គ.ជ.ប បានបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដោយមានគណបក្ស២បានដាក់បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយត្រូវបាន គ.ជ.ប យល់ព្រម និងបានធ្វើការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត គឺគណបក្សប្រជាជនកម្ពុជាបានលំដាប់លេខរៀងទី១ និងគណបក្សសមរង្ស៊ី បានលំដាប់លេខរៀងទី២។ អ្នកបោះឆ្នោត និងអង្គបោះឆ្នោតគឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង។ តាមការស្រង់ឈ្មោះអ្នកបោះឆ្នោតកន្លងមក នៅក្នុងបញ្ជីបោះឆ្នោតដំបូងដែលបិទផ្សាយកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១ មានចំនួនអ្នកបោះឆ្នោត**១១.៤៧២នាក់**។

គ.ជ.ប នឹងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនេះនៅថ្ងៃ១៤ ខែមករា គឺ ១៥ថ្ងៃមុនថ្ងៃបោះឆ្នោត។ បញ្ជីបោះឆ្នោតដែល គ.ជ.ប ផ្តល់សុពលភាពហើយមិនអាចកែប្រែបានឡើយ។ ការិយាល័យបោះឆ្នោតសរុបមាន**៣៣**ការិយាល័យ ជាទូទៅខេត្តនីមួយៗមានការិយាល័យបោះឆ្នោត១ ហើយខេត្តធំៗមានការិយាល័យបោះឆ្នោត២ ដោយឡែកខេត្តកំពង់ចាមមានការិយាល័យបោះឆ្នោត៣។

ក្នុងដំណាក់កាលនៃការបោះឆ្នោតជ្រើសតាំង

សមាជិកព្រឹទ្ធសភានេះ រចនាសម្ព័ន្ធរបស់ គ.ជ.ប ជារួមមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានអគ្គលេខាធិការដ្ឋានជាជំនួយការ និងនៅតាមរាជធានីខេត្ត មានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត មានគណៈកម្មការការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោត។ ចំណុចនេះមានការខុសប្លែកពីកាបោះឆ្នោតតំណាងរាស្ត្រ ឬក៏ការបោះឆ្នោតឃុំ សង្កាត់ ដែលយើងមានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

ជាមួយគ្នានេះដែរ កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១ ឯកឧត្តម ទេព នីថា ត្រូវបានកម្មវិធីស្វែងយល់អំពីការបោះឆ្នោតអញ្ជើញជាវាគ្មិន ដើម្បីធ្វើបទសម្ភាសន៍មួយទាក់ទងនឹងនីតិវិធីនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្តឹងតវ៉ា ឬជំទាស់នៅការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត។ ហើយព្រឹត្តិបត្រព័ត៌មាន គ.ជ.ប សូមធ្វើការចុះផ្សាយនូវបទសម្ភាសន៍នេះដូចខាងក្រោម ៖

**សំណួរ ៖ សូមជម្រាបសួរឯកឧត្តម តើនីតិវិធី និងការប្រព្រឹត្តទៅនៃការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោតយ៉ាងដូចម្តេចដែរ ?**

**ចម្លើយ ៖** ចំពោះនីតិវិធី និងការប្រព្រឹត្តទៅនៃការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ចែកជា៣ចំណុច ៖

*ទី១ អំពីការរៀបចំការិយាល័យបោះឆ្នោតនៅមុនការបើកការបោះឆ្នោត គឺពីម៉ោង៦ ដល់ម៉ោង៧ព្រឹក។*

*ទី២ ការប្រព្រឹត្តទៅនៃការបោះឆ្នោត ចាប់ផ្តើមពីម៉ោង៧ព្រឹក រហូតដល់ម៉ោង៣រសៀល។*

*ទី៣ អំពីការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត។*

**ចំណុចទី១** អំពីការរៀបចំការិយាល័យបោះឆ្នោតដែលជាទូទៅចាប់ផ្តើមពីម៉ោង៦ ទៅម៉ោង៧ព្រឹក។ តាមពិតទៅការរៀបចំការិយាល័យបោះឆ្នោតនេះ គឺត្រូវបានធ្វើតាំងពីមុនថ្ងៃបោះឆ្នោតមួយថ្ងៃ ដោយគណៈកម្មការការិយាល័យបោះឆ្នោត គាត់អញ្ជើញទៅធ្វើការបោសសំអាតរៀបចំនៅក្នុងការិយាល័យបោះឆ្នោត និងបិទផ្សាយបញ្ជីបោះឆ្នោតជាដើម។ ហើយនៅថ្ងៃបោះឆ្នោតមានការងារសំខាន់មួយចំនួន គឺសមាសភាពការិយាល័យបោះឆ្នោតត្រូវអញ្ជើញទៅដល់ការិយាល័យបោះឆ្នោតឱ្យទាន់ពេលវេលា គឺម៉ោង៦ព្រឹក ហើយបន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវដឹកនាំការងាររៀបចំការិយាល័យនេះ។ **ការងារទី១** គឺគាត់អញ្ជើញអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ តំណាងគណបក្សនយោបាយ រួមទាំងអ្នកសារព័ត៌មានដែលមាននៅទីនោះ ដើម្បីចូលក្នុងការិយាល័យបោះឆ្នោត និងត្រួតពិនិត្យមើលលិខិតអនុញ្ញាត ព្រមទាំងណែនាំអំពីបទបញ្ជានៅក្នុងការិយាល័យបោះឆ្នោត និងអញ្ជើញគាត់ទៅតាមទីកន្លែងដែលគាត់ត្រូវអនុវត្តការងារ។ **ការងារទី២** ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវដឹកនាំការត្រួតពិនិត្យសម្ភារបោះឆ្នោតមួយចំនួន។ ក្នុងនោះ ដំបូងគាត់ត្រូវត្រួតពិនិត្យមើលហិបឆ្នោត តើបានដំឡើងហើយ ឬនៅ? ក្នុងករណីដំឡើងត្រឹមត្រូវហើយ គាត់ត្រូវលើកបង្ហាញហិបឆ្នោតទទេ រួចបិទគម្របក្នុងនៃហិបឆ្នោតតាមនីតិវិធី ហើយបន្ទាប់មកចាក់សោឃុំនៅលើ



*សកម្មភាពចាក់សោឃុំនៅលើហិបឆ្នោត នាការបោះឆ្នោតកន្លងមក*

ហិបឆ្នោត និងចុងក្រោយគាត់សរសេរលេខកូដការិយាល័យបោះឆ្នោតនៅលើក្រដាសសពីរសន្លឹក ហើយបិទនៅសងខាងហិបឆ្នោតនោះ។ ជាបន្ត គាត់បញ្ជាឱ្យអនុប្រធានត្រួតពិនិត្យមើលសន្លឹកឆ្នោត តើសន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតនៅការិយាល័យនោះ ឬទេ? បើត្រឹមត្រូវហើយ អនុប្រធានត្រូវបើករាប់សន្លឹកឆ្នោតទាំងនោះ ហើយសន្លឹកឆ្នោតទាំងអស់នេះ ជាធម្មតានៅការិយាល័យនីមួយៗមានចំនួនលើសពីចំនួនអ្នកបោះឆ្នោតពី៥០សន្លឹកទៅ៩៩សន្លឹក។ ការត្រួតពិនិត្យបន្តទៀត ប្រធានត្រូវបើកកញ្ចប់ត្រាសម្ងាត់ ហើយបើកត្រាសម្ងាត់នោះយកទៅបោះនៅលើក្រដាសមួយ រួចបង្ហាញអ្នកសង្កេតការណ៍នៅទីនោះឱ្យចំណាំថាជារូបអ្វី? ត្រានេះមានសារៈសំខាន់ណាស់ ព្រោះថា ត្រូវបោះនៅលើខ្នងសន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតដែលត្រូវប្រើប្រាស់ផ្លូវការនៅក្នុងការិយាល័យបោះឆ្នោតនោះ ហើយចុងក្រោយបំផុត គាត់ធ្វើការត្រួតពិនិត្យលើសម្ភារផ្សេងៗទៀត ក្នុងនោះដែរគឺមានបន្ទប់សម្ងាត់ ទឹកខ្មៅលប់លាងមិនជ្រះ ដើម្បីឱ្យអ្នកដែលបានបោះឆ្នោតហើយជ្រលក់ដៃនៅក្នុងនោះ និងសម្ភារឯកសារសម្រាប់បម្រើការរាប់សន្លឹកឆ្នោតផង។ រាល់ការត្រួតពិនិត្យទាំងអស់នេះ គឺត្រូវធ្វើនៅចំពោះមុខវត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានដែលមានវត្តមាននៅទីនោះ ហើយរាល់សកម្មភាពទាំងអស់ត្រូវបានលេខាធិការកត់ត្រា និងបំពេញនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត។

**ចំណុចទី២** អំពីការប្រព្រឹត្តទៅនៃការបោះឆ្នោតដែលចាប់ផ្តើមពីម៉ោង៧ព្រឹក ហើយបញ្ចប់យ៉ាងយូរបំផុតត្រឹមម៉ោង៣រសៀល។ សមាសភាពការិយាល័យបោះឆ្នោតត្រូវទៅកាន់ទីកន្លែងរបស់គាត់តាមការកំណត់ ហើយប្រធានការិយាល័យបោះឆ្នោតប្រកាសបើកការបោះឆ្នោត។ មន្ត្រីដែលទទួលបន្ទុកសណ្តាប់ធ្នាប់ដែលយាមនៅមាត់ច្រកចូលនៅការិយាល័យបោះឆ្នោត អញ្ជើញអ្នកបោះឆ្នោតជាដំបូងចំនួន៤នាក់ ចូលទៅក្នុងការិយាល័យបោះឆ្នោត ហើយអ្នកបោះឆ្នោតត្រូវអនុវត្តតាមខ្សែសង្វាក់ការងារបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត។ ជាបឋម គាត់ត្រូវតែជួបលេខាធិការនៃគណៈកម្មការការិយាល័យបោះឆ្នោត ដោយបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ហើយលេខាធិការធ្វើការត្រួតពិនិត្យម្រាមដៃគាត់តើមានប្រឡាក់ទឹកខ្មៅលុបលាងមិនជ្រះទេ ក្នុងករណីមិនទាន់បានបោះឆ្នោតទេ ដៃរបស់គាត់គឺស្អាត បន្ទាប់មកត្រូវត្រួតពិនិត្យមើលផ្ទៀងផ្ទាត់ឈ្មោះគាត់ និងឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ទៅនឹងបញ្ជីបោះឆ្នោត ក្នុងករណីត្រឹមត្រូវហើយ លេខាបញ្ជូនឯកសារបញ្ជាក់អត្តសញ្ញាណទៅតុអនុប្រធាន ហើយអញ្ជើញអ្នកបោះឆ្នោតទៅតុអនុប្រធាន។ អនុប្រធានការិយាល័យបោះឆ្នោតត្រួតពិនិត្យមើល ហើយហែកសន្លឹកឆ្នោតជូនទៅអ្នកបោះឆ្នោត ដោយបោះត្រាសម្ងាត់នៅលើខ្នងសន្លឹកឆ្នោត និងធ្វើការបត់សន្លឹកឆ្នោតជាផ្នត់ទៅតាមការណែនាំ និងណែនាំ




*សកម្មភាពចូលក្នុងបន្ទប់សម្ងាត់ដើម្បីគូសសន្លឹកឆ្នោត នាការបោះឆ្នោតកន្លងមក*

អ្នកបោះឆ្នោតឱ្យចូលទៅកាន់បន្ទប់សម្ងាត់ដើម្បីគូសសន្លឹកឆ្នោត។ អ្នកបោះឆ្នោតនៅពេលចូលក្នុងបន្ទប់សម្ងាត់

តទៅទំព័រទី 10

# ការបោះឆ្នោតឡើងវិញ ជ្រើសរើសក្រុមប្រឹក្សាខណ្ឌ ពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១



អ្នកសង្កេតការណ៍សង្កេតមើលការបោះឆ្នោត



សកម្មភាពពិនិត្យបញ្ជីឈ្មោះមុនចូលបោះឆ្នោត



ការតម្រង់ជួរមុខការិយាល័យបោះឆ្នោត



ការពិនិត្យអត្តសញ្ញាណអ្នកបោះឆ្នោត



ការផ្តល់សន្លឹកឆ្នោតដល់អ្នកបោះឆ្នោត





សកម្មភាពរាប់សន្លឹកឆ្នោត




ការបោះឆ្នោត



ការជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ




សកម្មភាពបើកហិបឆ្នោត និងចាក់សន្លឹកឆ្នោត



សកម្មភាពរាប់សន្លឹកឆ្នោត

តមកពីទំព័រទី 7 **នីតិវិធីនៃការបោះឆ្នោត ការរាប់...**

បោះឆ្នោត គាត់អាចប្រើប៊ិចនៅក្នុងនោះ ឬក៏ប៊ិចដែលគាត់មានហើយ មិនអនុញ្ញាតឱ្យប្រើខ្មៅដៃទេ គាត់ត្រូវគូសលើប្រអប់បួនជ្រុងនៃគណបក្សនយោបាយដែលគាត់ពេញចិត្តលើសន្លឹកឆ្នោត និងបត់តាមលំដាប់លំដោយមកវិញ ហើយគាត់ចេញទៅកន្លែងហិបឆ្នោត នៅពេលទៅដល់ហិបឆ្នោត គាត់ត្រូវលើកសន្លឹកឆ្នោតដែលបត់រួចនោះបង្ហាញត្រាសម្ងាត់នៅខាងខ្នងសន្លឹកឆ្នោតទៅជំនួយការដែលឈរនៅជិតនោះ និងអ្នកសង្កេតការណ៍ ហើយដាក់សន្លឹកឆ្នោតទៅក្នុងហិបឆ្នោត បន្ទាប់មកគាត់ត្រូវជ្រលក់ម្រាមដៃទៅក្នុងទឹកខ្មៅលុបលាងមិនជ្រះ តាមការណែនាំរបស់ជំនួយការ ហើយចុងក្រោយបំផុត គាត់អញ្ជើញចេញពីការិយាល័យបោះឆ្នោតទៅតាមច្រកចេញដែលបានកំណត់ទុកជាមុន។



*សកម្មភាពជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ សម្រាប់ការបោះឆ្នោតកន្លងមក*

**ចំណុចទី៣** ចំពោះការប្រកាសបិទការិយាល័យបោះឆ្នោត នៅក្នុងករណីដែលឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីអ្នកបោះឆ្នោតបានបោះអស់នៅមុនម៉ោង៣រសៀល ប្រធានការិយាល័យបោះឆ្នោតអាចបិទការបោះឆ្នោតបាន។ ក្នុងករណីដល់ម៉ោង៣រសៀល ហើយនៅមានអ្នកបោះឆ្នោតនៅឈរតំរង់ជួរនៅបរិវេណខាងក្នុងការិយាល័យបោះឆ្នោត ឬក្នុងការិយាល័យបោះឆ្នោត គឺត្រូវរង់ចាំរហូតដល់អ្នកបោះឆ្នោតទាំងអស់នោះបានបោះឆ្នោតហើយ ទើបបិទការបោះឆ្នោតបាន។ ជាទូទៅការបិទការបោះឆ្នោត គឺចាប់ផ្តើមនៅក្នុងរង្វង់ម៉ោង៣ ហើយក្នុងករណីដែលគាត់បោះចប់មុនគឺគាត់អាចបិទមុន ការបិទការបោះឆ្នោតនេះត្រូវអនុវត្តទៅតាមនីតិវិធីនូវការងារមួយចំនួន **ការងារទី១** គឺការបិទហិបឆ្នោត ប្រធានការិយាល័យបោះឆ្នោតត្រូវដឹកនាំការបិទការិយាល័យបោះឆ្នោត ក្នុងនោះបិទហិបឆ្នោតដោយបិទមូលផ្និតប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ហើយបន្ទាប់មកយកក្រដាសស្តើងមួយបិទពីលើនោះ និងយកគំរបហិបឆ្នោតបិទពីលើដោយចាក់សោឃ្មុំពីរ។ **ការងារទី២** ត្រូវចាត់តាំងឱ្យអនុប្រធានធ្វើការផ្ទៀងផ្ទាត់។ អនុប្រធាន និងលេខាធិការធ្វើការផ្ទៀងផ្ទាត់អ្នកបោះឆ្នោតដែលមានគូសនៅក្នុងបញ្ជីបោះឆ្នោត និងផ្ទៀងផ្ទាត់សន្លឹកឆ្នោតដែលនៅសល់ និងគល់សន្លឹកឆ្នោត។ លេខាត្រូវរាប់ចំនួនអ្នកបោះឆ្នោតដោយផ្អែកលើបញ្ជីបោះឆ្នោតដែលមានគូសធីកថាបានមកបោះឆ្នោត បន្ទាប់មកធ្វើការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងចំនួនអ្នកបោះឆ្នោតនេះ ហើយរាយការណ៍ជូនប្រធាន។ ប្រធានត្រូវឱ្យជំនួយការចោះសន្លឹកឆ្នោតដែលនៅសល់ដើម្បីធ្វើមោឃភាព និងចុងក្រោយបំផុតគឺជាការធ្វើកំណត់ហេតុនៃការបោះឆ្នោត ប្រធានត្រូវណែនាំទៅលេខាធិការដើម្បីឱ្យបំពេញបន្ថែមព័ត៌មាននៅលើរបាយការណ៍បោះឆ្នោតទៅតាមទម្រង់ដែល គ.ជ.ប បានកំណត់ឱ្យ ហើយក្រោយពីបានបំពេញឯកសារត្រឹមត្រូវហើយ ប្រធាន និងលេខាធិការត្រូវចុះហត្ថលេខា និងបោះត្រាលើកំណត់ហេតុនេះ ហើយអញ្ជើញគណបក្សនយោបាយចុះហត្ថលេខាបើសិនជាគាត់យល់ព្រម បន្ទាប់មកប្រធានចាប់ផ្តើមរៀបចំដំណើរការទៅជំហានមួយទៀត គឺការរាប់សន្លឹកឆ្នោត។

**សំណួរ ៖ ចុះនីតិវិធីនៃការរាប់សន្លឹកឆ្នោតវិញ តើយ៉ាងដូចម្តេចដែរ ?**

**ចម្លើយ ៖** បន្ទាប់ពីការបិទការបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវដឹកនាំរៀបចំការរាប់សន្លឹកឆ្នោត ហើយដំណើរការទាំងអស់នេះត្រូវអនុវត្តនៅចំពោះមុខតំណាងគណបក្សនយោបាយ អង្គការសង្កេតការណ៍បោះឆ្នោត ព្រមទាំងអ្នកសារព័ត៌មានដែលមានវត្តមាននៅទីនោះ។

**ការងារទី១** គឺត្រូវរៀបចំការិយាល័យរាប់សន្លឹកឆ្នោត។ ការរៀបចំការិយាល័យរាប់សន្លឹកឆ្នោតត្រូវអនុវត្តតាមគំរូប្លង់ដែល គ.ជ.ប បានណែនាំ ក្នុងនោះមានការដាក់តុមួយធំវែង ឬក៏យកតុតូចៗតំរៀបគ្នាដាក់នៅចំកណ្ដាលបន្ទប់ ហើយយកហិបឆ្នោតដែលនៅឃុំនៅឡើយដាក់នៅចំកណ្ដាលតុនោះ និងដាក់កៅអី៤នៅជុំវិញនោះ គឺប្រធាន និងលេខាធិការត្រូវអង្គុយចុងតុម្ខាងម្នាក់ទល់មុខគ្នា ហើយជំនួយការ និងអនុប្រធានត្រូវអង្គុយសងខាងទល់មុខគ្នា។

**ការងារទី២** ការបើកហិបឆ្នោត និងការចាក់សន្លឹកឆ្នោតទៅលើតុរាប់សន្លឹកឆ្នោត ប្រធានត្រូវត្រួតពិនិត្យមើល



*សកម្មភាពចាក់សន្លឹកឆ្នោតទៅលើតុរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតកន្លងមក*

ហិបឆ្នោត មើលសោឃុំ ហើយបង្ហាញដល់គណបក្សនយោបាយ ឬអ្នកសង្កេតការណ៍នៅទីនោះឱ្យបានឃើញទាំងអស់គ្នា ហើយបន្ទាប់មកប្រធានត្រូវកាត់សោឃុំ និងចាក់សន្លឹកឆ្នោតនៅក្នុងហិបនោះមកលើតុរាប់សន្លឹកឆ្នោត។

**ការងារទី៣** ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ការងារនេះគឺប្រធានត្រូវបញ្ជាទៅអនុប្រធាន និងជំនួយការឱ្យលាសន្លឹកឆ្នោត ហើយរៀបសន្លឹកឆ្នោតជាពីរពុំនូក។ ពុំនូកទី១ ជាពុំនូកសន្លឹកឆ្នោតដែលមានត្រាសម្ងាត់នៅលើសន្លឹកឆ្នោត រួចចងវាជាបាច់ក្នុងមួយបាច់មាន២៥សន្លឹក។ ពុំនូកទី២ ជាពុំនូកសន្លឹកឆ្នោតដែលពុំមានត្រាសម្ងាត់លើខ្នងសន្លឹកឆ្នោត។ ក្រោយពីរៀបចំហើយ គាត់រាប់សន្លឹកឆ្នោតទាំងអស់ ហើយគាត់រាយការណ៍អំពីការងាររបស់គាត់ជូនទៅប្រធានការិយាល័យរាប់សន្លឹកឆ្នោត។

**ការងារទី៤** គឺការរាប់សន្លឹកឆ្នោត ប្រធានត្រូវត្រួតពិនិត្យជាបឋមលើសុពលភាពនៃសន្លឹកឆ្នោត គាត់ចាប់ផ្ដើមលើកសន្លឹកឆ្នោតដែលមានត្រាសម្ងាត់នៅខាងខ្នងបញ្ជាក់សុពលភាពមើលថា ត្រឹមត្រូវហើយ បន្ទាប់មកបានគាត់មើលការគូសសន្លឹកឆ្នោត តើគូសឱ្យគណបក្សណា ហើយគាត់ប្រកាសខ្លាំងៗ ពីលទ្ធផលនៃការបោះឆ្នោត និងលើកសន្លឹកឆ្នោតបង្ហាញទៅតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមាននៅទីនោះ បន្ទាប់មកលេខាធិការ និងអនុប្រធានត្រូវកត់ពិន្ទុទៅលើគណបក្សនយោបាយដែលបានទទួលសម្លេងឆ្នោត ហើយជំនួយការក៏ត្រូវគូសសម្លេងឆ្នោតនៅលើក្រដាសលទ្ធផលដែលមានឈ្មោះគណបក្សនីមួយៗ ដើម្បីបញ្ជាក់ពីលទ្ធផលនេះ ថាបានកត់ត្រាត្រឹមត្រូវហើយ។ ការរាប់សន្លឹកឆ្នោត ប្រសិនបើចាប់ផ្ដើមដំណើរការរាប់ហើយ គឺត្រូវអនុវត្តរហូតដល់ចប់ចុងចប់ដើម មិនអនុញ្ញាតឱ្យឈប់សម្រាកទេ។ ក្នុងដំណាក់កាលរាប់សន្លឹកឆ្នោតនេះ ប្រសិនបើមានការតវ៉ាលើសន្លឹកឆ្នោតណាមួយ ប្រធានត្រូវលើកសន្លឹកឆ្នោតនេះដាក់នៅខាងពុំនូកទី២ គឺខាងស្ដាំដៃដែលជាពុំនូកសន្លឹកឆ្នោតមិនបានការ ហើយពុំនូកសន្លឹកឆ្នោតមិនបានការនឹងត្រូវត្រួត



សកម្មភាពរៀបសន្លឹកឆ្នោតជាពុំទូកនៅការិយាល័យរាប់សន្លឹកឆ្នោតកន្លងមក

ពិនិត្យឡើងវិញក្រោយពីការបញ្ចប់ការរាប់សន្លឹកឆ្នោត នៅខាងពុំទូកទី១។ ចំពោះការងារបន្តមកទៀតក្រោយ ពីការរាប់សន្លឹកឆ្នោត គឺការប្រកាសលទ្ធផល និងការ បិទផ្សាយលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យ រាប់សន្លឹកឆ្នោត។ ប្រធានត្រូវណែនាំអំពីការធ្វើកំណត់ ហេតុនៃការរាប់សន្លឹកឆ្នោត បន្ទាប់មកគាត់ប្រកាស លទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅទីនោះ ដោយណែនាំ ឱ្យលេខាធិការយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នេះ យកមកដើម្បីចុះហត្ថលេខា និងបោះត្រា គាត់ អាចអញ្ជើញតំណាងគណបក្សនយោបាយចូលរួមចុះ ហត្ថលេខាលើកំណត់ហេតុនេះបើសិនជាយល់ព្រម ហើយបន្ទាប់មកត្រូវយកកំណត់ហេតុនៃការរាប់សន្លឹក ឆ្នោតនេះទៅបិទនៅការិយាល័យរាប់សន្លឹកឆ្នោតនៅ ល្ងាចនៃថ្ងៃបោះឆ្នោតនោះតែម្តង។ ប្រធានក៏ត្រូវណែនាំ ឱ្យបំពេញលើទម្រង់តារាងលទ្ធផលនៃកាបោះឆ្នោត ដើម្បី ចែកជូនឱ្យគណបក្សនយោបាយដែលមានវត្តមាននៅ ទីនោះដែរ។ នេះជាដំណើរការរួមនៃការបោះឆ្នោត និង រាប់សន្លឹកឆ្នោត។

បន្ទាប់ពីនេះប្រធានការិយាល័យបោះឆ្នោត រាប់ សន្លឹកឆ្នោត ត្រូវចាត់ការរៀបចំសម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកទាំងអស់តាមនីតិវិធី គ.ជ.ប រួចដឹកជញ្ជូន ទៅ គឃ/ខប នៅល្ងាចនោះ ដោយត្រូវរៀបចំការពារ សន្តិសុខឱ្យបានល្អ និងអញ្ជើញតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ចូលរួមផង។

**សំណួរ ៖ ទាក់ទងនឹងការប្តឹងតវ៉ា ឬជំទាស់ និង ការដោះស្រាយបណ្តឹងក្នុងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងលើលទ្ធផលនៃការបោះឆ្នោត តើធ្វើយ៉ាងដូចម្តេចដែរ?**

**ចម្លើយ ៖** បើយើងនិយាយតាមនីតិវិធី គឺមាន ដំណាក់កាលច្បាស់លាស់ ហើយមានបែបបទដែលត្រូវ បំពេញឱ្យបានច្បាស់លាស់ ទាំងអ្នកប្តឹង ទាំងអ្នកទទួល បណ្តឹង ទាំងអ្នកដោះស្រាយបណ្តឹង។ ការប្តឹងអាចចែក ក្នុងការអនុវត្តជាក់ស្តែងជា៣ដំណាក់កាល។

**ដំណាក់កាលទី១** ការប្តឹងនៅពេលកំពុងដំណើរ ការបោះឆ្នោត ឬក៏រាប់សន្លឹកឆ្នោត។ អ្នកប្តឹងជាតំណាង គណបក្សនយោបាយដែលពិនិត្យមើលការបោះឆ្នោតនៅ ក្នុងការិយាល័យបោះឆ្នោតនោះ ក្នុងករណីគាត់ឃើញ ដំណើការរៀបចំការបោះឆ្នោត ឬឃើញអ្វីមួយដែលមិន ប្រក្រតី គាត់អាចប្តឹងទៅប្រធានការិយាល័យបោះឆ្នោត។ ប្រធានការិយាល័យបោះឆ្នោតទទួលបណ្តឹង ហើយក្នុង ករណីដែលចាំបាច់ គាត់អាចផ្អាកការបោះឆ្នោត ហើយ អញ្ជើញមន្ត្រីការិយាល័យបោះឆ្នោតទាំងអស់ជួបពិភាក្សាគ្នា ដើម្បីសម្រេចទៅលើបណ្តឹងនោះ ហើយឆន្ទានុសិទ្ធិប្រធាន ការិយាល័យគាត់មានសិទ្ធិសម្រេច។ គាត់អាចសម្រេចលើ បណ្តឹងនេះ ហើយគាត់អាចបន្តការងារនៅក្នុងការិយាល័យ បន្តទៅទៀត។ ក្នុងករណីគណបក្សមិនពេញចិត្ត គាត់អាច ប្តឹងបន្តមកទៀត តែបណ្តឹងរបស់គាត់អាចនឹងត្រូវកត់ត្រានៅ ក្នុងកំណត់ហេតុ ល្គឹកណាតែគាត់យល់ព្រមចុះហត្ថលេខា នៅលើកំណត់ហេតុ។ នេះជាបណ្តឹងនៅពេលកំពុងបោះ ឆ្នោត ឬពេលរាប់សន្លឹកឆ្នោត។

តទៅទំព័រទី 15

# ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ បានបញ្ចប់ទៅដោយរលូន និងគ្មានបណ្តឹង

ខណ្ឌពោធិ៍សែនជ័យជាខណ្ឌមួយទើបបង្កើតថ្មីតាមអនុក្រឹត្យលេខ៨០ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១។ ខណ្ឌនេះស្ថិតនៅក្នុងរាជធានីភ្នំពេញ មានសង្កាត់ចំនួន១៣ ដែលកាត់ចេញពីខណ្ឌដង្កោ គឺសង្កាត់ចោមចៅ សង្កាត់កាកាប សង្កាត់ក្រាំងធ្នង់ សង្កាត់គោករកា សង្កាត់សំរោងក្រោម សង្កាត់ពន្សាំង សង្កាត់ត្រពាំងក្រសាំង សង្កាត់ឪឡោក សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់បឹងធំ សង្កាត់ស្នោរ និងសង្កាត់ភ្លើងឆេះរទេះ។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានតម្រូវឱ្យ គ.ជ.ប រៀបចំការបោះឆ្នោតឡើងវិញសម្រាប់ជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌដែលបង្កើតថ្មី ក្នុងរយៈពេលយ៉ាងយូរ ២៤០ថ្ងៃ បន្ទាប់ពីថ្ងៃបង្កើតខេត្ត ក្រុង ស្រុក ខណ្ឌនោះ។



***ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប***

ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា តើហេតុអ្វីបានជាហៅថាការបោះឆ្នោតឡើងវិញសម្រាប់ខណ្ឌពោធិ៍សែនជ័យនេះ ព្រោះថា ការបោះឆ្នោតនេះជាការបោះឆ្នោតបង្គ្រប់អាណត្តិដែលគេបានបោះឆ្នោតកាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩កន្លងមក។ ដូចនេះហើយបានជាគេហៅថា ការបោះឆ្នោតឡើងវិញ ដែលភាសាអង់គ្លេសហៅថា By-Election។

តាមអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យចែងថា សមាជិកក្រុមប្រឹក្សាខណ្ឌនេះមានចំនួន១៩នាក់។ ទោះបីការបោះឆ្នោតឡើងវិញនេះធ្វើឡើងតែមួយខណ្ឌក៏ដោយ តាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតនេះតាមប្រតិទិនការងារដូចការបោះឆ្នោតទូទៅដែរ មានដូចជា ការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងការដោះស្រាយបណ្តឹងនៅគ្រប់ដំណាក់កាលទាំងអស់។

គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតនេះមាន២គណបក្ស គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសម រង្ស៊ី ហើយគណបក្សទាំង២នេះបានធ្វើការឃោសនាទៅតាមកម្មវិធីរៀងៗខ្លួនរួមមាន ៖

**១-សកម្មភាពឃោសនារបស់គណបក្សប្រជាជនកម្ពុជាបានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម ៖**

-ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ បានរៀបចំប្រជុំជារូបភាពធំនៅសួនច្បារដង្កោ ដែលមានអ្នកចូលរួមប្រមាណ៥០០នាក់ រួមមានរថយន្តធំ រថយន្តតូច និងម៉ូតូជាច្រើនគ្រឿង។

-ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១១ បានរៀបចំប្រជុំជារូបភាពធំ ហែក្បួនចេញពីសួនច្បារដង្កោ ដែលមាន





*សន្និសីទសារព័ត៌មានផ្សព្វផ្សាយអំពីព្រឹត្តិការណ៍ទូទៅ និងលទ្ធផលបឋមនៃការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ*

រថយន្តធំចំនួន០៩គ្រឿង រថយន្តតូច២០គ្រឿង និងអ្នកចូលរួមប្រមាណប្រហែលជាង៣៥០នាក់។

-ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១ តាមប្រតិទិនរបស់គណបក្សប្រជាជនកម្ពុជា មានការរៀបចំជារូបភាពធំ ហែក្បួនចែកជា២ ក្បួនទី១ហែឆ្លងកាត់ទឹកដី០៤សង្កាត់ គឺសង្កាត់ចោមចៅ ភ្លើងឆេះរទេះ បឹងធំ និងសង្កាត់កន្ទោក និងក្បួនទី២ហែកាត់០៩សង្កាត់ គឺសង្កាត់កាកាប ក្រាំងធ្នង់ គោករកា សំរោងក្រោម ត្រពាំងក្រសាំង ស្នោរ ឪឡោក ពន្សាំង និងសង្កាត់កំបូល។

**២_សកម្មភាពឃោសនារបស់គណបក្សសមរង្ស៊ី បានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម ៖**

-ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១១ នៅទីស្នាក់ការគណបក្សសម រង្ស៊ីសង្កាត់កាកាប បានរៀបចំប្រជុំសមាជិកទាំង១៣សង្កាត់ និងមានរូបភាពវីដេអូខន់ហ្វឺរិនផងដែរ។

-ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ នៅទីស្នាក់ការគណបក្សសម រង្ស៊ីសង្កាត់សំរោងក្រោម មានរៀបចំកិច្ចប្រជុំសមាជិកក្រុមប្រឹក្សា សមាជិករដ្ឋសភារបស់គណបក្ស ដែលមានអ្នកចូលរួមប្រមាណ៧០នាក់។

-ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១ គណបក្សសម រង្ស៊ីសង្កាត់ដង្កោ បានដង្ហែក្បួនសំដៅទៅសង្កាត់ទាំង១៣ ក្នុងនោះមានរថយន្តធំ០១គ្រឿង រថយន្តតូច០៦គ្រឿង ម៉ូតូ៣០គ្រឿង និងអ្នកចូលរួមប្រមាណជាង១០០នាក់។

ក្រៅពីរូបភាពដង្ហែក្បួន និងប្រមូលផ្តុំសមាជិកសមាជិកា គណបក្សទាំង២ក៏មានការឃោសនាតាមរូបភាពតូចៗ ដូចជាការចាក់មេក្រូ និងប្រជុំសមាជិកនៅតាមទីស្នាក់ការគណបក្សរបស់ខ្លួន។

ជាលទ្ធផលការឃោសនាបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូន ពុំមានអំពើហិង្សា ការរំលោភបំពានច្បាប់ និងពុំមានបណ្តឹងឡើយ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ បានប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី១១ ខែធ្នូ ឆ្នាំ២០១១ ក្រោមការឃ្លាំមើលពីតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ។ ទីតាំងការិយាល័យបោះឆ្នោតស្ថិតនៅវិទ្យាល័យហ៊ុនសែនជម្ពូវ័ន្ត ហើយអ្នកមានសិទ្ធិបោះឆ្នោតចំនួន៨៩នាក់ គឺសមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងតំណែងទាំង១៣សង្កាត់។ នៅម៉ោង៧:០០នាទីព្រឹក ការិយាល័យបោះឆ្នោតបានបើកការបោះឆ្នោត ហើយក្រោយពីដំណើរការ

បោះឆ្នោតអស់រយៈពេលជាង១ម៉ោង គឺនៅម៉ោង ៨:២០នាទីព្រឹក ការបោះឆ្នោតត្រូវបានបិទ ព្រោះអ្នកបោះឆ្នោតបានបោះឆ្នោតគ្រប់គ្នាទាំងអស់។ ការរាប់សន្លឹកឆ្នោតក៏ត្រូវបានដំណើរការតាមនីតិវិធី។ ក្រោយពេលការរាប់សន្លឹកឆ្នោតបានបញ្ចប់ លទ្ធផលនៃការបោះឆ្នោត ក៏ត្រូវបានបិទផ្សាយនៅមុខការិយាល័យបោះឆ្នោតនាថ្ងៃនោះដែរ។ (*សូមមើលរូបភាពនៅទំព័រទី៨ និងទី៩* )

ជាមួយគ្នានេះ នៅរសៀលថ្ងៃដដែលនាទីស្តីការ គ.ជ.ប ក៏បានធ្វើសន្និសីទសារព័ត៌មានមួយផ្សព្វផ្សាយអំពីលទ្ធផលនៃការបោះឆ្នោតនេះផងដែរ។



***ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក គ.ជ.ប***

ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក គ.ជ.ប បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មានថា ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត បានប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា គ្មានបណ្តឹង ហើយបន្ទាប់ពីការរាប់សន្លឹកឆ្នោត គណបក្សប្រជាជនកម្ពុជាទទួលបាន៦៧សម្លេង និងគណបក្សសម រង្ស៊ី ទទួលបាន២២សម្លេង។

លទ្ធផលផ្លូវការនៃការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ ដោយគណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈចំនួន១៥ និងគណបក្សសម រង្ស៊ី ទទួលបានអាសនៈចំនួន៤៕

***តមកពីទំព័រទី 12*** ***នីតិវិធីនៃការបោះឆ្នោត ការរាប់...***

**ដំណាក់កាលទី២** បណ្តឹងនៅក្រោយការបោះឆ្នោត គណបក្សនយោបាយអាចប្តឹងទៅគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតរហូតដល់ម៉ោង១១ និង៣០នាទី នៃថ្ងៃក្រោយថ្ងៃបោះឆ្នោត។ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ និងធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យដែលមាននៅក្នុងរាជធានីខេត្តរបស់ខ្លួន ហើយព្រមជាមួយនោះធ្វើការផ្ទៀងផ្ទាត់ និងដោះស្រាយបណ្តឹង។

ក្នុងករណីដែលអ្នកប្តឹងមិនពេញចិត្ត អាចធ្វើការប្តឹងតវ៉ាមក គ.ជ.ប។ គាត់ប្តឹងក្នុងរយៈពេល២ថ្ងៃ គ.ជ.ប ធ្វើការដោះស្រាយបណ្តឹងក្នុងរយៈពេល២ថ្ងៃ អញ្ចឹងទេ ការសម្រេចនៅលើដំណាក់កាលនៃការប្តឹងនេះគឺចប់ត្រឹម គ.ជ.ប។ **ដំណាក់កាលទី៣** ក្រោយពីការដោះស្រាយបណ្តឹង គ.ជ.ប ធ្វើការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅតាមភូមិភាគ។ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គណបក្សនយោបាយអាចធ្វើការប្តឹងទៅលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅ គ.ជ.ប ក្នុងរយៈពេល ៧២ម៉ោង គ.ជ.ប ធ្វើការដោះស្រាយក្នុងរយៈពេល ៤៨ម៉ោង ហើយក្នុងករណីដែលគាត់មិនពេញចិត្តនឹងការសម្រេចរបស់ គ.ជ.ប គាត់អាចប្តឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ម៉ោង ហើយក្រុមប្រឹក្សាធម្មនុញ្ញធ្វើការដោះស្រាយក្នុងរយៈពេលពី១០ទៅ២០ថ្ងៃ។ ទាំងអស់នេះជាការប្តឹង និងការដោះស្រាយបណ្តឹងនៅក្នុងដំណាក់កាលនៃការបោះឆ្នោត រាប់សន្លឹកឆ្នោត រហូតដល់ការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត៕

# សកម្មភាពកិច្ចប្រជុំ-សន្និសីទសារព័ត៌មានផ្សព្វផ្សាយអំពីការងារបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២




កិច្ចប្រជុំកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១




កិច្ចប្រជុំកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១




សន្និសីទសារព័ត៌មានកាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១